**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ០៧ សរណន**

# សារាចរណែនាំ

# ស្តីពី

# ការប្រើប្រាស់សេវារថយន្តប្រណិត

កន្លងមក ដើម្បីសម្រួលដល់ការដឹកជញ្ជូនគណៈប្រតិភូ និងភ្ញៀវបរទេសនានា ដែលមកបំពេញទស្សនកិច្ចការងារ នៅព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានផ្តល់ការអនុញ្ញាតអោយដល់គ្រប់ក្រសួង-ស្ថាប័នប្រើប្រាស់នូវសេវារថយន្តប្រណិត ដែលគ្រប់គ្រងដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ចំពោះមុខដើម្បី ឆ្លើយតបនឹងទំហំនៃសេចក្តីត្រូវការរបស់គ្រប់បណ្តាក្រសួង-ស្ថាប័ននានា របស់រាជរដ្ឋាភិបាល ជាពិសេសដូចនៅពេល មានព្រឹត្តិការណ៍ធំៗ ឬពេលកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះសម្រាប់ការរៀបចំកិច្ចប្រជុំថ្នាក់តំបន់ ឬអន្តរជាតិផ្សេងៗ និងដើម្បីធានាអោយការដឹកជញ្ជូនគណៈប្រតិភូ និងភ្ញៀវបរទេសនានា ដែលមកបំពេញទស្សន កិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា អោយបានសមរម្យ ប្រកបដោយសុវត្ថិភាព និងរក្សាបាននូវកិត្យានុភាពជាតិ ស្របតាមការរីកចំរើនរបស់ប្រទេសនាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលបានផ្តល់សិទ្ធិផ្តាច់មុខអោយក្រុមហ៊ុន Royal Cambodian Limousine Service Co., Ltd ដើម្បីផ្គត់ផ្គង់សេវារថយន្តប្រណិត អោយដល់គ្រប់ក្រសួង-ស្ថាប័ន មានជាអាទិ៍ ក្រសួង អាជ្ញាធរ ក្រុមប្រឹក្សា គណៈកម្មាធិការ គណៈកម្មការ និងអង្គភាពនានា ទាំងថ្នាក់ជាតិ ទាំងថ្នាក់រាជធានី ខេត្ត នៃរាជរដ្ឋាភិបាល ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន ដូចតទៅ៖

(១)- គ្រប់ក្រសួង-ស្ថាប័ន ត្រូវប្រើប្រាស់សេវារថយន្តប្រណិតនេះ សម្រាប់រាល់ការដឹកជញ្ជូនគណៈប្រតិភូ និងភ្ញៀវបរទេស ដែលមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា ដោយពុំអនុញ្ញាតអោយប្រើប្រាស់សេវា របស់ក្រុមហ៊ុនឯកជនណាផ្សេងទៀតឡើយ ។

(២)- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនត្រូវផ្តល់ថវិកា ទូទាត់ដល់ក្រសួង-ស្ថាប័នណា ដែលប្រើប្រាស់សេវាដឹក ជញ្ជូនរបស់ក្រុមហ៊ុនឯកជនផ្សេង ក្រៅពីក្រុមហ៊ុន Royal Cambodian Limousine Service Co., Ltd នេះទេ ។

(៣)- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវចេញសារាចរណែនាំលំអិតដល់គ្រប់ក្រសួង-ស្ថាប័ន អំពីការប្រើប្រាស់ សេវារថយន្តប្រណិតនេះ ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន នៃរាជរដ្ឋាភិបាល ត្រូវយកចិត្តទុកដាក់អនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ៖ លោក ឈឹម ទីណា